**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ឯកសារយុទ្ធសាស្ត្រ
# ស្តីពី
# ការគ្រប់គ្រងបំណុលសាធារណៈ
# ២០១៥-២០១៨

**រៀបចំដោយ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# អារម្ភកថា

រាជរដ្ឋាភិបាលបានអនុម័តឯកសារយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១-២០១៨ ដែលជាយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈលើកទី១ របស់កម្ពុជា កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១២ និងបានប្រកាសដាក់ឱ្យអនុវត្តនៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២។

តាមរយៈយុទ្ធសាស្ត្ររយៈពេល ០៨ ឆ្នាំនេះ រាជរដ្ឋាភិបាលបានកំណត់ទំហំនៃការខ្ចីថ្មីបន្ថែមសម្រាប់ឆ្នាំ ២០១១-២០១៨ ក្នុងរង្វង់ពី ៤០០ លាន ទៅ ៧០០ លានអេសដេអ៊ែរ ក្នុងមួយឆ្នាំ និងបានដាក់ចេញនូវវិធានការគោលនយោបាយចំនួន ០៨ ចំណុច ដើម្បីធានាបាននូវប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

រាជរដ្ឋាភិបាលបានកត់សម្គាល់ឃើញថា លើមូលដ្ឋាននៃយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១-២០១៨ ការគ្រប់គ្រងបំណុលសាធារណៈនៅកម្ពុជាសម្រេចបាននូវសមិទ្ធផលគួរជាទីមោទនៈ។ ផ្អែកតាមលទ្ធផលនៃការវិភាគចីរភាពបំណុល ស្ថានភាពបំណុលសាធារណៈកម្ពុជាបច្ចុប្បន្នមាន "**ចីរភាព**" និង "**ហានិភ័យកម្រិតទាប**"។ លទ្ធផលនេះ ក៏ត្រូវបានវាយតម្លៃ និងទទួលស្គាល់ ដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ ដូចជា៖ មូលនិធិរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក, និងធនាគារអភិវឌ្ឍន៍អាស៊ី ផងដែរ។ ជាក់ស្តែង ពិន្ទុនៃការវាយតម្លៃសូចនាករគោលនយោបាយបំណុលរបស់កម្ពុជា រៀបចំដោយធនាគារអភិវឌ្ឍន៍អាស៊ី បានកើនពី ៤,០ ពិន្ទុ នៅឆ្នាំ២០១០ ទៅ ៤,៥ ពិន្ទុ នៅឆ្នាំ២០១១ និង ៥,០ ពិន្ទុ ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៤ ធៀបនឹងពិន្ទុអតិបរិមា ៦,០។

រាជរដ្ឋាភិបាលសូមធ្វើការវាយតម្លៃខ្ពស់ចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលបានសកម្មចូលរួមអនុវត្តយ៉ាងម៉ឺងម៉ាត់ នូវរាល់វិធានការគោលនយោបាយដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១១-២០១៨ និងសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានបំពេញភារកិច្ចយ៉ាងខ្ជាប់ខ្ជួន ក្នុងឋានៈជាសេនាធិការរបស់រាជរដ្ឋាភិបាលលើកិច្ចការគ្រប់គ្រងបំណុលសាធារណៈ ក្នុងការដឹកនាំអនុវត្តយុទ្ធសាស្ត្រនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានទាំងនេះ រាជរដ្ឋាភិបាលនៅតែពិនិត្យឃើញមានបញ្ហាប្រឈមធំៗមួយចំនួន ដែលកំពុងបន្តជះឥទ្ធិពលលើការគ្រប់គ្រងបំណុលសាធារណៈ ទាំងក្នុងពេលបច្ចុប្បន្ន និងទាំងក្នុងពេលអនាគត រួមមាន៖ (១) ភាពរឹងស្អូតនៃហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទានខ្ពស់ នៅពេលដែលសេដ្ឋកិច្ចកម្ពុជាកំពុងតែអភិវឌ្ឍន៍រីកចម្រើនធំធាត់ ក្នុងដំណើរបោះជំហានយ៉ាងស្វាហាប់ ចាកចេញពីឋានៈប្រទេសមានចំណូលទាប ទៅឋានៈប្រទេសមានចំណូលមធ្យមកម្រិតទាប; (២) លទ្ធភាពនៃការធ្លាក់ចុះអតិរេកចរន្តសម្រាប់ចំណាយគម្រោងវិនិយោគផ្ទាល់ ក្នុងបរិការណ៍ដែលរាជរដ្ឋាភិបាលបន្តអនុវត្តគោលនយោបាយដំឡើងប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដើម្បីឈានទៅសម្រេចគោលដៅឱ្យបានជាង ១លានរៀល ក្នុងមួយខែ នៅឆ្នាំ២០១៨; (៣) ហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុដែលអាចកើតចេញ ពីការធានារបស់រដ្ឋលើគម្រោងវិនិយោគតាមយន្តការភាពជាដៃគូ

រវាងរដ្ឋនិងឯកជន (PPP) និង ពីវិស័យធនាគារនិងហិរញ្ញវត្ថុ; និង (៤) ប្រសិទ្ធភាពនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។ល។

ចំពោះមុខបញ្ហាប្រឈមខាងលើ និងដោយពិនិត្យឃើញសភាពការណ៍វិវឌ្ឍថ្មីៗក្នុងវិស័យគ្រប់គ្រងបំណុលសាធារណៈ ទាំងក្នុងកម្រិតតំបន់ និងទាំងក្នុងកម្រិតសកលលោក ព្រមទាំងអនុលោមតាមមាត្រា៦៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងមាត្រា២៧ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ រាជរដ្ឋាភិបាលបានធ្វើការត្រួតពិនិត្យឡើងវិញ លើការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១-២០១៨ និងបានធ្វើបច្ចុប្បន្នកម្មក្នុងគោលបំណងបន្តធានាសង្គតិភាព និងភាពប្រទាក់ក្រឡាជាមួយគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ ដោយកំណត់ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ ៦០០ លានអេសដេអ៊ែរ សម្រាប់ឆ្នាំ២០១៥ និងក្នុងរង្វង់ពី ៧០០ លាន ទៅ ៨០០ លានអេសដេអ៊ែរ ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១៦-២០១៨ ព្រមទាំងបានដាក់ចេញនូវវិធានការគោលនយោបាយចំនួន ០៨ ចំណុចផ្សេងទៀត ដោយរួមមានទាំងគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ ដើម្បីបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលវែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប សំដៅរួមចំណែកជំរុញចីរភាពកំណើនសេដ្ឋកិច្ចរយៈពេលវែង និងលើកស្ទួយកម្រិតជីវភាពប្រជាជន។

ក្នុងបណ្តាវិធានការគោលនយោបាយទាំងនេះ រាជរដ្ឋាភិបាលយល់ឃើញថា កិច្ចការពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ គឺជាវិធានការគោលនយោបាយអាទិភាពមួយដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបន្តជំរុញល្បឿននៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ក្នុងបរិការណ៍ដែលបញ្ហាប្រឈមកំពុងមានឥទ្ធិពលលើការគ្រប់គ្រងបំណុលសាធារណៈកម្ពុជា។ ក្នុងន័យនេះ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការមុតស្រួចបន្ថែមមួយចំនួន រួមមាន៖ (១) ការរៀបចំក្របខ័ណ្ឌគោលនយោបាយរួមសម្រាប់គ្រប់គ្រងចំណាយវិនិយោគសាធារណៈ ប្រកបដោយភាពគ្រប់ជ្រុងជ្រោយនិងប្រទាក់ក្រឡា ដោយត្រូវគ្របដណ្តប់ទាំងគម្រោងវិនិយោគផ្ទាល់ដោយថវិកាជាតិ, គម្រោងវិនិយោគហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍, និងទាំងគម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន; និង (២) ការបន្តពង្រឹងនីតិវិធីប្រតិបត្តិការ និងគោលការណ៍ណែនាំសម្រាប់គ្រប់គ្រងនិងអនុវត្តគម្រោងវិនិយោគសាធារណៈ សំដៅជានាបង្កើនប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, និងគណនេយ្យភាពនៃចំណាយវិនិយោគសាធារណៈ។

ទន្ទឹមនេះ រាជរដ្ឋាភិបាលមើលឃើញថា សេដ្ឋកិច្ចសកលលោក, សេដ្ឋកិច្ចតំបន់, និងសេដ្ឋកិច្ចកម្ពុជាបាននិងកំពុងវិវឌ្ឍក្នុងចលនការរស់រវើក ចារឹកដោយ ភាពប្រទាក់ក្រឡា និងភាពមានឥទ្ធិពលចំពោះគ្នាទៅវិញទៅមក រវាងវិស័យឯកជន និងវិស័យសាធារណៈ។ ក្នុងន័យនេះ ជាចក្ខុវិស័យសម្រាប់រយៈពេលមធ្យម និងវែង រាជរដ្ឋាភិបាលនឹងពង្រីកវិសាលភាពនៃការគ្រប់គ្រងបំណុល ឱ្យគ្របដណ្តប់លើបំណុលរួមរបស់ជាតិទាំងមូល ដោយត្រូវបញ្ចូលទាំងបំណុលរបស់វិស័យឯកជន ជាពិសេស បំណុលក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ ដើម្បីរួមចំណែកក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ចក្នុងរយៈពេលវែង។

រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងមុតមាំថា ក្រសួង ស្ថាប័នពាក់ព័ន្ធ នឹងបន្តចូលរួមសហការពេញលេញជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការអនុវត្តរាល់វិធានការគោលនយោបាយដែលបានដាក់ចេញក្នុងឯកសារយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ ប្រកបដោយប្រសិទ្ធភាពខ្ពស់ សំដៅបន្តចូលរួមលើកស្ទួយចីរភាពកំណើនសេដ្ឋកិច្ចរយៈពេលវែង និងការទ្រទ្រង់វិស័យសង្គមកិច្ច ដើម្បីសមធម៌ និងយុត្តិធម៌សង្គម។

*រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# បុព្វកថា

# បុព្វកថា

ដោយទទួលបានការកិច្ចដ៏ឧត្តុងឧត្តមពីរាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំឯកសារយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១-២០១៨ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន និងគោលការណ៍គន្លឹះទាំង ០៤ របស់សម្តេចតេជោ ដែលរួមមាន៖

១) ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន

២) ត្រូវខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់

៣) ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពកំណើន និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច

៤) ត្រូវប្រើប្រាស់ឥណទានទាំងនោះ ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធិភាពខ្ពស់បំផុត។

យុទ្ធសាស្ត្រនេះ ត្រូវបានអនុម័តដោយសម្តេចតេជោនាយករដ្ឋមន្ត្រី កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១២ និងត្រូវបានប្រកាសដាក់ឱ្យអនុវត្តនៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២។ យុទ្ធសាស្ត្រនេះ បានកំណត់ទំហំនៃការខ្ចីថ្មីបន្ថែមសម្រាប់ឆ្នាំ២០១១-២០១៨ ក្នុងរង្វង់ពី ៤០០ លាន ទៅ ៧០០ លានអេសដេអ៊ែរ ក្នុងមួយឆ្នាំ និងបានដាក់ចេញនូវវិធានការគោលនយោបាយចំនួន ០៨ ចំណុចផ្សេងទៀត សំដៅធានាបាននូវប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្នុងរយៈពេលកន្លងទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឋានៈជាសេនាធិការរបស់រាជរដ្ឋាភិបាល លើកិច្ចការគ្រប់គ្រងបំណុលសាធារណៈ បានតាមដាន និងត្រួតពិនិត្យដោយយកចិត្តទុកដាក់លើការអនុវត្តយុទ្ធសាស្ត្រនេះ រហូតឈានទៅសម្រេចបាននូវសមិទ្ធផលធំៗ រួមមាន៖ (១) ការគ្រប់គ្រងបាននូវទំហំនៃការខ្ចីមិនឱ្យលើសពីពិដានកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ; (២) ការសម្រិតសម្រាំងយកតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់; (៣) ការប្រើប្រាស់ឥណទានសម្បទានចំគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាល ដោយក្នុងនោះ ប្រមាណ ៨០% សម្រាប់ការវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងប្រមាណ ២០% សម្រាប់ការវិនិយោគលើវិស័យអាទិភាពផ្សេងទៀត; និង (៤) ការរក្សាបាននូវចីរភាពបំណុលសាធារណៈ និងការកម្រិតហានិភ័យបំណុលឱ្យនៅទាប។

បើទោះបីជាសម្រេចបាននូវសមិទ្ធផលដ៏ធំធេងយ៉ាងនេះក្តី កិច្ចការគ្រប់គ្រងបំណុលសាធារណៈរបស់កម្ពុជា នៅតែជួបនូវបញ្ហាប្រឈមដែលចាំបាច់ត្រូវបន្តខិតខំដោះស្រាយ។ ទន្ទឹមនេះ តាមការសិក្សាស្រាវជ្រាវភាគច្រើននៃប្រទេសដែលបរាជ័យក្នុងកិច្ចការគ្រប់គ្រងបំណុលសាធារណៈ គឺបណ្តាលមកពី៖ (១) កង្វះខាតនៃក្របខ័ណ្ឌគតិយុត្ត និងគោលនយោបាយ និង (២) ភាពទន់ខ្សោយនៃយន្តការនិងសមត្ថភាពស្ថាប័ន ក្នុងការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ ដែលបង្កឡើងដោយព្រឹត្តិហេតុផ្ទៃក្នុង និង/ឬ ផ្ទៃក្រៅ។

ក្នុងន័យនេះ ការត្រួតពិនិត្យមើលឡើងវិញលើការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ

២០១១-២០១៨ និងការធ្វើបច្ចុប្បន្នកម្មឱ្យទៅជាយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ ត្រូវបានធ្វើឡើងដោយប្រយ័ត្នប្រយែង និងយកចិត្តទុកដាក់លើបញ្ហាប្រឈម, បទពិសោធន៍នៃបណ្តាប្រទេសនានាលើសកលលោក, និងបរិការណ៍វិវឌ្ឍនៃសេដ្ឋកិច្ច-សង្គមកម្ពុជា ព្រមទាំងបានដាក់ចេញនូវវិធានការគោលនយោបាយចំនួន ០៩ ចំណុច ដូចខាងក្រោម៖

១- កំណត់ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ ៦០០ លានអេសដេអ៊ែរ សម្រាប់ឆ្នាំ២០១៥ និងក្នុងរង្វង់ពី ៧០០ លាន ទៅ ៨០០ លានអេសដេអ៊ែរ ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១៦-២០១៨ ទៅតាមបរិការណ៍នៃគោលនយោបាយថវិកា និងវិវឌ្ឍនាការម៉ាក្រូសេដ្ឋកិច្ចជាក់ស្តែងរបស់កម្ពុជា។ សម្រាប់ឆ្នាំ២០១៥-២០១៨ ជារួមរាជរដ្ឋាភិបាលនឹងមិនបោះផ្សាយមូលបត្ររដ្ឋ ឬសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យដែលជាឧបករណ៍បំណុលថ្មីទេ តែក៏អាចធ្វើការសាកល្បងប្រើប្រាស់ឧបករណ៍ថ្មីនេះនៅពេលណាមួយ សម្រាប់ជាការចាប់ផ្តើមនៃទីផ្សារបំណុល (មូលបត្ររដ្ឋ) និងអាចជាមូលដ្ឋានសម្រាប់ឱ្យមានការបោះផ្សាយមូលបត្រឯកជន។

២- បន្តប្រើប្រាស់ឥណទានសម្បទានសម្រាប់ហិរញ្ញប្បទានលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ និងវិស័យបង្កើនផលិតភាពផលិតកម្ម សំដៅទ្រទ្រង់ចីរភាពកំណើនរយៈពេលវែង។

៣- បន្តពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ទាំងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ, ក្របខ័ណ្ឌហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍, និងទាំងក្នុងក្របខ័ណ្ឌវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP)។

៤- បន្តទទួលយកតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់។

៥- បន្តអនុវត្តគោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យសំខាន់ៗ សំដៅសម្រេចបាននូវចីរភាពកំណើនសេដ្ឋកិច្ចរយៈពេលមធ្យម ក្នុងរង្វង់ ៧ ភាគរយ និងកំណើនចំណូលថវិកាជាតិក្នុងរង្វង់ជាមធ្យម ០,៥ ពិន្ទុភាគរយ នៃ ផសស ក្នុងមួយឆ្នាំ។

៦- បន្តអនុវត្តគោលការណ៍មជ្ឈការក្នុងការគ្រប់គ្រងបំណុលសាធារណៈ។

៧- បន្តពង្រឹងការកៀរគរហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានពីប្រភពផ្សេងទៀត សម្រាប់បំពេញតម្រូវការវិនិយោគសាធារណៈសរុប។

៨- បន្តពង្រឹងការតាមដាន និងត្រួតពិនិត្យលើហានិភ័យបំណុលពាក់ព័ន្ធ ជាពិសេស ហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុដែលអាចកើតចេញ ពីការធានារបស់រដ្ឋលើគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP) និង ពីវិស័យធនាគារនិងហិរញ្ញវត្ថុ។

៩- បន្តពង្រឹងការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាពស្ថាប័ន ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ឱ្យមានប្រសិទ្ធភាពខ្ពស់។

ទន្ទឹមនេះ ក្រោមការចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការ៖ (១) បន្តពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ តាមរយៈការរៀបចំក្របខ័ណ្ឌគោលនយោបាយរួម, នីតិវិធីប្រតិបត្តិការ, និងគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ និង (២) រៀបចំក្របខ័ណ្ឌគោលនយោបាយសម្រាប់ការ

គ្រប់គ្រងបំណុលរួមរបស់ជាតិទាំងមូល ឱ្យគ្របដណ្តប់ទាំងបំណុលរបស់វិស័យឯកជន ជាពិសេស បំណុលក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានកិច្ចសហការពេញលេញពីក្រសួង ស្ថាប័នពាក់ព័ន្ធ នឹងបន្តប្រកាន់ខ្ជាប់នូវវិន័យម៉ឺងម៉ាត់ក្នុងការអនុវត្តវិធានការគោលនយោបាយដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ សំដៅធានាចីរភាពបំណុលសាធារណៈ, ស្ថិរភាពហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច, ព្រមទាំងរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនឱ្យបានយ៉ាងតិចជាង ១ ភាគរយក្នុងមួយឆ្នាំ។

*រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៥*

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

# ខ្លឹមសារសង្ខេប

# នៃ

# ឯកសារយុទ្ធសាស្ត្រ

# ស្តីពី

# ការគ្រប់គ្រងបំណុលសាធារណៈ

# ២០១៥-២០១៨

## ខ្លឹមសារសង្ខេបនៃ
## ឯកសារយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨

រាជរដ្ឋាភិបាលបានអនុម័តឯកសារយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១-២០១៨ ដែលជាយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈលើកទី១ របស់កម្ពុជា កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១២ និងបានប្រកាសដាក់ឱ្យអនុវត្តនៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២។

យុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន និងគោលការណ៍គន្លឹះទាំង ០៤ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមាន៖

១) ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន

២) ត្រូវខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់

៣) ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពកំណើន និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច និង

៤) ត្រូវប្រើប្រាស់ឥណទានទាំងនោះ ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធិភាពខ្ពស់បំផុត។

តាមរយៈយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលបានកំណត់ទំហំនៃការខ្ចីថ្មីបន្ថែមសម្រាប់ឆ្នាំ២០១១-២០១៨ ក្នុងរង្វង់ពី ៤០០ លាន ទៅ ៧០០ លានអេសដេអ៊ែរ ក្នុងមួយឆ្នាំ និងបានដាក់ចេញនូវវិធានការគោលនយោបាយចំនួន ០៨ ចំណុចផ្សេងទៀត សំដៅធានាបាននូវប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ។

ដោយពិនិត្យឃើញសភាពការណ៍វិវឌ្ឍថ្មីៗក្នុងវិស័យគ្រប់គ្រងបំណុលសាធារណៈ ទាំងក្នុងកម្រិតតំបន់ និងទាំងក្នុងកម្រិតសកលលោក ព្រមទាំងអនុលោមតាមមាត្រា៦៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងមាត្រា២៧ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ រាជរដ្ឋាភិបាលបានត្រួតពិនិត្យឡើងវិញលើការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១-២០១៨ និងបានធ្វើបច្ចុប្បន្នកម្មឱ្យទៅជាយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ ដើម្បីធានាឱ្យមានសង្គតិភាព និងភាពប្រទាក់ក្រឡាគ្នាជាមួយគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធ ដែលកិច្ចការទាំងនេះ ជាសកម្មភាពត្រូវសម្រេចឱ្យបានក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - ដំណាក់កាលទី២។

យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ មានគោលបំណងធានានូវប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, និងគណនេយ្យភាព ក្នុងការគ្រប់គ្រងបំណុលសាធារណៈ សំដៅបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលវែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប ដោយធានាបាននូវសង្គតិភាព និងភាពប្រទាក់ក្រឡាគ្នាជាមួយឯកសារយុទ្ធសាស្ត្រ និងគោលនយោបាយពាក់ព័ន្ធនានា រួមមាន៖ ១) យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី៣, ២) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨, ៣) គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច, ៤) គោលនយោបាយថវិកា, ៥) គោលនយោបាយរូបិយវត្ថុ, ៦) យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០, ៧) គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥, និង ៨) យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨។ល។

យុទ្ធសាស្ត្រនេះ មានគោលដៅកំណត់នូវ វិធានការគោលនយោបាយ សំដៅពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាពក្នុងរយៈពេលវែង។

យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ នេះ មានវិសាលភាពគ្របដណ្តប់លើរាល់ប្រតិបត្តិការពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈរបស់រដ្ឋ និងមិនគ្របដណ្តប់លើបំណុលរបស់វិស័យឯកជនទេ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលមើលឃើញថា សេដ្ឋកិច្ចសកលលោក, សេដ្ឋកិច្ចតំបន់, និងសេដ្ឋកិច្ចកម្ពុជា បាននិងកំពុងវិវឌ្ឍក្នុងចលនការរស់រវើក ចារឹកដោយ ភាពប្រទាក់ក្រឡា និងភាពមានឥទ្ធិពលចំពោះគ្នាទៅវិញទៅមក រវាងវិស័យឯកជន និងវិស័យសាធារណៈ។ ក្នុងន័យនេះ ជាចក្ខុវិស័យសម្រាប់រយៈពេលមធ្យម និងវែង រាជរដ្ឋាភិបាលនឹងពង្រីកវិសាលភាពនៃការគ្រប់គ្រងបំណុល ឱ្យគ្របដណ្តប់លើបំណុលរួមរបស់ជាតិទាំងមូល ដោយត្រូវបញ្ចូលទាំងបំណុលរបស់វិស័យឯកជន ជាពិសេស បំណុលក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ ដើម្បីរួមចំណែកក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ចក្នុងរយៈពេលវែង។

តាមរយៈការអនុវត្តយ៉ាងម៉ឺងម៉ាត់តាមបទដ្ឋានបច្ចេកទេសអន្តរជាតិ ព្រមទាំងគោលការណ៍ និងវិន័យនៃការគ្រប់គ្រងបំណុលសាធារណៈ បានធ្វើឱ្យស្ថានភាពនៃការគ្រប់គ្រងបំណុលសាធារណៈរបស់កម្ពុជាកាន់តែវិវឌ្ឍទៅរកភាពរីកចម្រើនជាបន្តបន្ទាប់។ ផ្អែកតាមលទ្ធផលនៃការវិភាគចីរភាពបំណុលដោយប្រយ័ត្នប្រយែង និងគ្រប់ជ្រុងជ្រោយ ស្ថានភាពបំណុលសាធារណៈកម្ពុជាបច្ចុប្បន្នមាន **"ចីរភាព"** និង **"ហានិភ័យកម្រិតទាប"**។ លទ្ធផលនេះ ក៏ត្រូវបានវាយតម្លៃនិងទទួលស្គាល់ ដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ ដូចជា៖ មូលនិធិរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក, និងធនាគារអភិវឌ្ឍន៍អាស៊ី ជាដើម។ ជាក់ស្តែង ពិន្ទុនៃការវាយតម្លៃសូចនាករគោលនយោបាយបំណុលរបស់កម្ពុជា រៀបចំដោយធនាគារអភិវឌ្ឍន៍អាស៊ី បានកើនពី ៤,០ ពិន្ទុ នៅឆ្នាំ២០១០ ទៅ ៤,៥ ពិន្ទុ នៅឆ្នាំ២០១១ និង ៥,០ ពិន្ទុ ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៤ ធៀបនឹងពិន្ទុអតិបរមា ៦,០។ សមិទ្ធផលទាំងនេះ ជាសក្ខីភាពបង្ហាញថា រាជរដ្ឋាភិបាលបាននិងកំពុងដើរនៅលើផ្លូវដ៏ត្រឹមត្រូវក្នុងការគ្រប់គ្រងបំណុលសាធារណៈ ប្រកបដោយចីរភាព។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានទាំងនេះ រាជរដ្ឋាភិបាលនៅតែពិនិត្យឃើញនូវបញ្ហាប្រឈមធំៗមួយចំនួន ដែលកំពុងបន្តជះឥទ្ធិពលលើការគ្រប់គ្រងបំណុលសាធារណៈកម្ពុជា ទាំងក្នុងពេលបច្ចុប្បន្ន និងទាំងក្នុងពេលអនាគត។

ជាក់ស្តែង នៅពេលដែលសេដ្ឋកិច្ចកម្ពុជាកាន់តែអភិវឌ្ឍន៍រីកចម្រើនធំជាត់ ក្នុងដំណើរបោះជំហានយ៉ាងស្វាហាប់ ចាកចេញពីឋានៈប្រទេសមានចំណូលទាប ទៅឋានៈប្រទេសមានចំណូលមធ្យមកម្រិតទាបនោះ ហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទានខ្ពស់សម្រាប់កម្ពុជា នឹងកាន់តែរីងស្ងួតទៅៗ ដោយដៃគូអភិវឌ្ឍន៍នឹងផ្លាស់ប្តូរគោលនយោបាយ តាមរយៈការកាត់បន្ថយ ឬលែងផ្តល់ហិរញ្ញប្បទានឥតសំណងឱ្យកម្ពុជាតែម្តង។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលចាំបាច់ត្រូវធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យមានលក្ខណៈទូលំទូលាយជាងមុន ដើម្បីបំពេញតម្រូវការវិនិយោគសាធារណៈសរុបក្នុងវិស័យអាទិភាពរបស់ខ្លួន។

ម្យ៉ាងវិញទៀត ចាប់ពីឆ្នាំ២០១៥ ទៅ អតិរេកចរន្តសម្រាប់ចំណាយគម្រោងវិនិយោគផ្ទាល់នឹងកាន់តែខើចទៅៗ ដោយសារចំណាយចរន្តរបស់រដ្ឋនឹងមានការកើនឡើងមួយកម្រិត ក្នុងបរិការណ៍ដែលរាជរដ្ឋាភិបាលបន្តអនុវត្តគោលនយោបាយដំឡើងប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដើម្បីឈានទៅសម្រេចគោលដៅឱ្យបានជាង ១លានរៀល ក្នុងមួយខែ នៅឆ្នាំ២០១៨។ ក្នុងស្ថានការណ៍នេះ

រាជរដ្ឋាភិបាលចាំបាច់ត្រូវមានភាពហ្មត់ចត់ក្នុងការបន្ត៖ (១) ពង្រឹងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨; (២) បង្កើនការសន្សំសំចៃខ្ពស់តាមរយៈការធ្វើវិចារណកម្មចំណាយ; (៣) ពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ; និង (៤) ពង្រឹងការកៀរគរហិរញ្ញប្បទាន ពីដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងទៀត សម្រាប់បំពេញតម្រូវការវិនិយោគសាធារណៈសរុប។

ទន្ទឹមនេះដែរ បំណុលចាស់ ឬបំណុលជាមរតក ក៏នៅតែជាបញ្ហាប្រឈមដែលរាជរដ្ឋាភិបាលត្រូវខិតខំដោះស្រាយឱ្យបានជ្រះស្រឡះ ដើម្បីបើកផ្លូវឱ្យមានកិច្ចសហប្រតិបត្តិការស៊ីជម្រៅពេញលេញលើគ្រប់វិស័យ ជាមួយដៃគូពាក់ព័ន្ធទាំងនោះ។ បើទោះបីជាយ៉ាងនេះក្តី ការដោះស្រាយត្រូវមានការប្រុងប្រយ័ត្ន និងមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ចីរភាពបំណុលសាធារណៈរបស់កម្ពុជាឡើយ។

ការកត់ត្រាទិន្នន័យកាតព្វកិច្ចបំណុលជាយថាហេតុឱ្យមានលក្ខណៈប្រមូលផ្តុំ និងគ្រប់ជ្រុងជ្រោយក៏នៅតែជាបញ្ហាចោទនៅឡើយ សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ជាពិសេស ទិន្នន័យពាក់ព័ន្ធនឹងការធានាក្រោមក្របខ័ណ្ឌនៃការអនុវត្តគម្រោងវិនិយោគតាមយន្តការ PPP/BOT ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា៖ ផ្លូវថ្នល់, ស្ពាន, ផ្លូវដែក, អាកាសយានដ្ឋាន, កំពង់ផែ។ល។ ដែលទាមទារឱ្យមានកិច្ចសហការខ្ពស់ពីក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល។ ទន្ទឹមនេះ បំណុលរបស់សហគ្រាសសាធារណៈ (SOEs) ក៏ពុំទាន់ត្រូវបានសិក្សាឱ្យស៊ីជម្រៅនៅឡើយ ហើយដែលបំណុលនេះនឹងក្លាយជាបំណុលសាធារណៈរបស់រដ្ឋ ប្រសិនបើសហគ្រាសសាធារណៈណាមួយមិនអាចមានលទ្ធភាពសងគេបាន។

ធនធានមនុស្សក្នុងកិច្ចការគ្រប់គ្រងបំណុល នៅពុំទាន់អាចឆ្លើយតបបានតាមតម្រូវការការងារបច្ចុប្បន្ន ក៏ដូចជាទៅអនាគតនៅឡើយ ដែលកត្តានេះ ទាមទារឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវ៖ ១) ជ្រើសរើសមន្ត្រីថ្មីដែលមានសមត្ថភាពបន្ថែម, ២) បន្តពង្រឹងការបណ្តុះបណ្តាលលើការងារវិភាគ និងការងារជំនាញពាក់ព័ន្ធ, និង ៣) ចាត់វិធានការចាំបាច់នានាដើម្បីរក្សាទុកមន្ត្រីដែលមានសមត្ថភាព និងឆន្ទៈវិជ្ជាជីវៈខ្ពស់តាមរយៈការពិនិត្យឡើងវិញលើប្រព័ន្ធផ្តល់ការលើកទឹកចិត្ត។

ក្នុងបរិការណ៍ខាងលើ ដើម្បីបន្តរក្សាចីរភាពបំណុលសាធារណៈ និងកម្រិតហានិភ័យបំណុលឱ្យនៅទាប សំដៅរួមចំណែកក្នុងការជំរុញចីរភាពកំណើនសេដ្ឋកិច្ចរយៈពេលវែង និងលើកស្ទួយកម្រិតជីវភាពប្រជាជន រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការគោលនយោបាយចំនួន ០៩ ចំណុច សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០១៥-២០១៨ ដូចខាងក្រោម៖

១- កំណត់ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ ៦០០ លានអេសដេអ៊ែរ សម្រាប់ឆ្នាំ២០១៥ និងក្នុងរង្វង់ពី ៧០០ លាន ទៅ ៨០០ លានអេសដេអ៊ែរ ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១៦-២០១៨ ទៅតាមបរិការណ៍នៃគោលនយោបាយថវិកា និងវិវឌ្ឍនាការម៉ាក្រូសេដ្ឋកិច្ចជាក់ស្តែងរបស់កម្ពុជា។

សម្រាប់ឆ្នាំ ២០១៥- ២០១៨ ជារួម រាជរដ្ឋាភិបាលនឹងមិនបោះផ្សាយមូលបត្ររដ្ឋ ឬសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យដែលជាឧបករណ៍បំណុលថ្មីទេ តែក៏អាចធ្វើការសាកល្បងប្រើប្រាស់ឧបករណ៍ថ្មីនេះនៅពេលណាមួយ សម្រាប់ជាការចាប់ផ្តើមនៃទីផ្សារបំណុល (មូលបត្ររដ្ឋ) និងអាចជាមូលដ្ឋានសម្រាប់ឱ្យមានការបោះផ្សាយមូលបត្រឯកជន។

២- ប្រើប្រាស់ឥណទានសម្បទានសម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ និងវិស័យបង្កើនផលិតភាពផលិតកម្ម សំដៅទ្រទ្រង់ចីរភាពកំណើនរយៈពេលវែង ដូចជា៖ ផ្លូវ

ថ្នល់, ស្ពាន, ប្រព័ន្ធស្រោចស្រព, អគ្គិសនី, កំពង់ផែ, ការផ្គត់ផ្គង់ទឹកស្អាតនៅទីប្រជុំជន, ស្ថានីយ៍សម្អាតទឹកកខ្វក់, និងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម ជាដើម។

៣- បន្តពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ទាំងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ, ក្របខ័ណ្ឌហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍, និងទាំងក្នុងក្របខ័ណ្ឌវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP)។ ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់ចែង៖ (១) រៀបចំក្របខ័ណ្ឌគោលនយោបាយរួមសម្រាប់គ្រប់គ្រងចំណាយវិនិយោគសាធារណៈ ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡា ដោយត្រូវគ្របដណ្តប់ទាំងគម្រោងវិនិយោគផ្ទាល់ដោយថវិកាជាតិ, គម្រោងវិនិយោគហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍, និងទាំងគម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP); និង (២) បន្តពង្រឹងនីតិវិធីប្រតិបត្តិការ និងគោលការណ៍ណែនាំសម្រាប់គ្រប់គ្រងនិងអនុវត្តគម្រោងវិនិយោគសាធារណៈ សំដៅជានាបង្កើនប្រសិទ្ធិភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, និងគណនេយ្យភាពនៃចំណាយវិនិយោគសាធារណៈ។

៤- បន្តទទួលយកតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់។

៥- បន្តអនុវត្តគោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យសំខាន់ៗ សំដៅសម្រេចបាននូវចីរភាពកំណើនសេដ្ឋកិច្ចរយៈពេលមធ្យម ក្នុងរង្វង់ ៧ ភាគរយ និងកំណើនចំណូលថវិកាជាតិ ក្នុងរង្វង់ជាមធ្យម ០,៥ ពិន្ទុភាគរយ នៃ ផសស ក្នុងមួយឆ្នាំ។

៦- បន្តអនុវត្តគោលការណ៍មជ្ឈការណ៍នៃការគ្រប់គ្រងបំណុលសាធារណៈ ដែលតាមនេះ *"មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែមួយគត់ ក្រោមការប្រទានសិទ្ធិពីនាយករដ្ឋមន្ត្រី ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ, ការបោះផ្សាយមូលបត្ររដ្ឋ, ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ, ការវិនិយោគ, ការធានានិងការសន្យាផ្នែកហិរញ្ញវត្ថុនានា, ការឱ្យប្រាក់គេខ្ចី ទាំងក្នុងនិងក្រៅប្រទេស, និងការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ។ គ្មានរដ្ឋមន្ត្រីដទៃណាទៀត ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ប្រធានសហគ្រាសសាធារណៈ អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ឬមន្ត្រីសាធារណៈណាមួយ មានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ, ឱ្យប្រាក់គេខ្ចី, ចេញលិខិតធានា, ឬ ក៏ធ្វើទង្វើណាផ្សេងៗទៀតដោយផ្ទាល់ ឬ ដោយប្រយោល ដែលអាចនាំឱ្យកើតមាននូវបំណុល ឬ បន្ទុកហិរញ្ញវត្ថុផ្សេងទៀត ដោយផ្ទាល់ ឬ ដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជាបានទេ។"*

៧- បន្តពង្រឹងការកៀរគរហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានពីប្រភពផ្សេងទៀត សម្រាប់បំពេញតម្រូវការវិនិយោគសាធារណៈសរុប។ ជាមួយគ្នានេះ ត្រូវរក្សាភាពទន់ភ្លន់ក្នុងការប្រើប្រាស់ឥណទានដែលមានកម្រិតសម្បទានខ្ពស់ សម្រាប់ហិរញ្ញប្បទានគម្រោងក្នុងវិស័យសង្គមកិច្ច ក្នុងគោលដៅទាក់ទាញ និងកៀរគរហិរញ្ញប្បទានឥតសំណង ដើម្បីបំពេញតម្រូវការហិរញ្ញប្បទានគម្រោងសរុប និងជួយសម្រាលបន្ទុកសេវាបំណុល។

ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវដឹកមុខក្នុងការសិក្សារៀបចំបង្កើតក្របខ័ណ្ឌគតិយុត្តសម្រាប់គ្រប់គ្រងគម្រោងតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា ដែលអាចទាក់ទាញការចូលរួមពីវិស័យឯកជន ឱ្យបានឆាប់បំផុត។

៨- បន្តពង្រឹងការតាមដាន និងត្រួតពិនិត្យលើហានិភ័យបំណុលពាក់ព័ន្ធ ជាពិសេស ហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលអាចកើតចេញ ពីការធានារបស់រដ្ឋលើគម្រោងភាពជាដៃគូរវាងរដ្ឋ និង

ឯកជន (PPP) និង ពីវិស័យធនាគារនិងហិរញ្ញវត្ថុ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការគន្លឹះបន្ថែម ដូចខាងក្រោម៖

- ជានាទូទាត់គម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP) ត្រឹមកម្រិតដែលស្ថានភាពថវិកា និងសេដ្ឋកិច្ច អាចទ្រាំទ្របាន។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តខិតខំរៀបចំគោលនយោបាយស្តីពីការធានារបស់រដ្ឋ ដើម្បីដាក់ឱ្យអនុវត្តក្នុងពេលដ៏ខ្លីខាងមុខ។
- បង្កើតមូលនិធិបម្រុង (Contingency Fund) សម្រាប់ត្រៀមដោះស្រាយការធានាទូទាត់របស់រដ្ឋលើគម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP)។
- ធនាគារជាតិនៃកម្ពុជា ត្រូវសិក្សាគ្រប់ជ្រុងជ្រោយលើហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុដែលអាចកើតចេញពីវិស័យធនាគារនិងហិរញ្ញវត្ថុ ដើម្បីដាក់ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈពិភាក្សា និងស្នើវិធានការដោះស្រាយ ក្នុងករណីចាំបាច់។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដឹកមុខក្នុងការរៀបចំក្របខ័ណ្ឌគោលនយោបាយសម្រាប់ការគ្រប់គ្រងបំណុលរួមរបស់ជាតិទាំងមូល ឱ្យគ្របដណ្តប់ទាំងបំណុលសាធារណៈ និងទាំងបំណុលរបស់វិស័យឯកជន ជាពិសេស បំណុលក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ។

ទន្ទឹមនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចូលរួមសហការអនុវត្តតាមវិធានការលម្អិតនីមួយៗ ដែលបានដាក់ចេញក្នុងឯកសារគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ ២០១៥-២០១៨ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ជៀសវាងភាពចន្លោះប្រហោងជាយថាហេតុដែលនាំឱ្យមានការកើតឡើងនូវហានិភ័យធ្ងន់ធ្ងរហួសពីភាពដែលអាចគ្រប់គ្រងបាន។

*៩*- បន្តពង្រឹងការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាពស្ថាប័ន ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ឱ្យមានប្រសិទ្ធភាពខ្ពស់។

រាជរដ្ឋាភិបាល នឹងបន្តតាមដានយ៉ាងយកចិត្តទុកដាក់លើដំណើរការនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ នេះ ដើម្បីធានាបាននូវប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការចូលរួមលើកស្ទួយចីរភាពកំណើនសេដ្ឋកិច្ច ក្នុងរយៈពេលវែង និងការទ្រទ្រង់វិស័យសង្គមកិច្ច ដើម្បីសមធម៌ និងយុត្តិធម៌សង្គម៕